**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**ក្រសួងមហាផ្ទៃ**

លេខ: ០១៤ [illegible]

# សេចក្តីណែនាំ

## ស្តីពី

## ការបែងចែកប្រាក់រង្វាន់លើកទឹកចិត្ត

## ជូនរដ្ឋបាលថ្នាក់ក្រោមជាតិលើការផ្តល់សេវារដ្ឋបាល

យោងតាមអនុក្រឹត្យលេខ៦៨ អនក្រ.បក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ប្រកាសអន្តរក្រសួងលេខ ៣៨៥៦ ប្រក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៣ របស់ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ប្រកាសអន្តរក្រសួងលេខ៣៨៤៥ ប្រក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៣ របស់ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់រង្វាន់លើកទឹកចិត្តជូនរដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងដើម្បីធានាឲ្យការបែងចែកប្រាក់រង្វាន់លើកទឹកចិត្ត ដែលបានមកពីការផ្តល់សេវារដ្ឋបាលសម្រាប់ឧបត្ថម្ភជូនមន្ត្រី បុគ្គលិកដែលផ្តល់សេវាផ្ទាល់ និងមន្ត្រី បុគ្គលិកផ្សេងៗទៀត ព្រមទាំងពង្រឹងយន្តការផ្តល់សេវារដ្ឋបាល ដោយផ្អែកលើគោលការណ៍តម្លាភាព សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ ក្រសួងមហាផ្ទៃសូមធ្វើការណែនាំដូចខាងក្រោម ៖

**ក. គោលការណ៍**

- ចំណែកប្រាក់រង្វាន់ដែលត្រូវបានអនុញ្ញាតឲ្យកាត់ទុកជាមុន សម្រាប់ផ្តល់ជូនរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមន្ទីរ អង្គភាពជំនាញ ត្រូវផ្អែកតាមសមាមាត្រភាគរយតាមវិស័យនីមួយៗ និងតាមប្រភេទរដ្ឋបាលនីមួយៗដូចមានកំណត់ក្នុងតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសអន្តរក្រសួងលេខ ៣៨៤៥ ប្រក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្តីពីការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តជូនរដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ការបែងចែកប្រាក់រង្វាន់លើកទឹកចិត្តជូនមន្ត្រី បុគ្គលិកដែលផ្តល់សេវាផ្ទាល់ និងមន្ត្រី បុគ្គលិកផ្សេងៗទៀត ព្រមទាំងពង្រឹងយន្តការផ្តល់សេវារដ្ឋបាល ត្រូវផ្អែកលើគោលការណ៍តម្លាភាព សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ
- ការបែងចែកប្រាក់រង្វាន់លើកទឹកចិត្តជូនមន្ត្រី បុគ្គលិកដែលផ្តល់សេវាផ្ទាល់ និងមន្ត្រី បុគ្គលិកផ្សេងៗទៀត ត្រូវធ្វើការទូទាត់ប្រចាំខែ ជារៀងរាល់ដំណាច់ខែនីមួយៗ

- ការបែងចែកប្រាក់រង្វាន់លើកទឹកចិត្តជូនមន្ត្រី បុគ្គលិកដែលផ្តល់សេវាផ្ទាល់ និងមន្ត្រី បុគ្គលិកផ្សេងៗទៀត ព្រមទាំងពង្រឹងយន្តការផ្តល់សេវារដ្ឋបាល ត្រូវអនុលោមតាមការសម្រេចរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ និងផ្អែកតាមសេចក្តីណែនាំនេះ។

## ខ. ប្រភពប្រាក់រង្វាន់លើកទឹកចិត្ត

ប្រភពប្រាក់រង្វាន់លើកទឹកចិត្តលើការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិរួមមាន ៖

១. ចំណែកប្រាក់រង្វាន់ដែលបានមកពីការផ្តល់សេវារដ្ឋបាលដោយរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗផ្ទាល់

២. ចំណែកប្រាក់រង្វាន់ដែលបានមកពីការបែងចែកពីក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា

៣. ចំណែកប្រាក់រង្វាន់ដែលបានមកពីការបែងចែកពីថ្នាក់រដ្ឋបាលផ្សេងៗទៀត

## គ. ការបែងចែកប្រាក់រង្វាន់លើកទឹកចិត្ត

ប្រាក់រង្វាន់លើកទឹកចិត្តដែលបានមកពីការបូកសរុបរួមពីគ្រប់ប្រភពទាំងអស់ ដូចមានកំណត់ក្នុងចំណុច"**ខ**"ខាងលើ ត្រូវធ្វើការបែងចែកតាមការសម្រេចចិត្តពីក្រុមប្រឹក្សារបស់ខ្លួនសម្រាប់ឧបត្ថម្ភជូនមន្ត្រីបុគ្គលិក តាមសំណើរបស់អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដោយមានការឯកភាពពីគណៈអភិបាលរបស់ខ្លួន និងតាមសំណើរបស់មេឃុំ ចៅសង្កាត់ ដោយមានការពិគ្រោះយោបល់និងឯកភាពជាមួយជំទប់ ចៅសង្កាត់រងរបស់ខ្លួន។ ការបែងចែកប្រាក់រង្វាន់លើកទឹកចិត្តនេះ ត្រូវគោរពតាមការកំណត់ដូចខាងក្រោម ៖

- ការបែងចែកប្រាក់រង្វាន់សម្រាប់ឧបត្ថម្ភជូនមន្ត្រី បុគ្គលិក ត្រូវកំណត់យ៉ាងទាប**៧០%** នៃប្រាក់រង្វាន់សរុប និង
- ការបែងចែកប្រាក់រង្វាន់សម្រាប់ពង្រឹងយន្តការផ្តល់សេវារដ្ឋបាល ត្រូវកំណត់មិនឲ្យទាបជាង**១០%** និងមិនឲ្យច្រើនជាង**៣០%** នៃប្រាក់រង្វាន់សរុប។

ផលបូកសរុបនៃភាគរយសម្រាប់បែងចែកប្រាក់រង្វាន់ដល់មន្ត្រី បុគ្គលិក និងចំណែកប្រាក់រង្វាន់សម្រាប់ពង្រឹងយន្តការផ្តល់សេវារដ្ឋបាល ត្រូវស្មើនឹង១០០%។

### គ១. ការបែងចែកប្រាក់រង្វាន់លើកទឹកចិត្តសម្រាប់ឧបត្ថម្ភដល់មន្ត្រី បុគ្គលិក

#### គ.១.១. សម្រាប់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

ការបែងចែកប្រាក់រង្វាន់លើកទឹកចិត្តសម្រាប់ឧបត្ថម្ភជូនមន្ត្រី បុគ្គលិកនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើឡើងតាមការសម្រេចរបស់ក្រុមប្រឹក្សា តាមសំណើរបស់អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌសាមីនីមួយៗ ដោយមានការឯកភាពពីគណៈអភិបាលរបស់ខ្លួន។

ប្រាក់រង្វាន់នេះ ត្រូវធ្វើការបែងចែកសម្រាប់ឧបត្ថម្ភជូនមន្ត្រី បុគ្គលិកដែលផ្តល់សេវាផ្ទាល់ និងមន្ត្រីបុគ្គលិកផ្សេងៗទៀតដែលបំពេញការងារនៅរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ផ្អែកតាម **លទ្ធផលនិងប្រសិទ្ធភាពការងាររបស់**មន្ត្រី បុគ្គលិកម្នាក់ៗ។

ប្រាក់រង្វាន់សម្រាប់បែងចែកជូន**មន្ត្រី បុគ្គលិកម្នាក់ៗដែលផ្តល់សេវាផ្ទាល់** ត្រូវកំណត់មិនឲ្យទាប**ជាង២ដង និងមិនឲ្យច្រើនជាង៣ដង**នៃប្រាក់រង្វាន់សម្រាប់ឧបត្ថម្ភជូន**មន្ត្រី បុគ្គលិកម្នាក់ៗនៃមន្ត្រី បុគ្គលិកផ្សេងៗទៀត**ឡើយ។

មន្ត្រីទីប្រឹក្សា មន្ត្រីកិច្ចសន្យាដែលគាំទ្រដោយមូលនិធិរបស់ដៃគូអភិវឌ្ឍន៍នានា និងសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មិនត្រូវទទួលបានប្រាក់រង្វាន់នេះឡើយ។

នាយករដ្ឋបាលសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើការពិភាក្សាពិគ្រោះយោបល់ជាមួយប្រធានអង្គភាពនានានៃសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីផ្តួចផ្តើមរៀបចំសេចក្តីព្រាងតារាងបែងចែកប្រាក់រង្វាន់សម្រាប់មន្ត្រី បុគ្គលិកដែលផ្តល់សេវាផ្ទាល់ និងមន្ត្រី បុគ្គលិកផ្សេងៗទៀតដែលត្រូវទទួលបានប្រាក់រង្វាន់លើកទឹកចិត្តនៅរដ្ឋបាលរបស់ខ្លួន តាមតារាងគំរូក្នុងឧបសម្ព័ន្ធទី១នៃសេចក្តីណែនាំនេះ ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ស្តីពីលទ្ធផលនៃការផ្តល់សេវារដ្ឋបាលរបស់ខ្លួន ដូចមានទម្រង់គំរូក្នុងឧបសម្ព័ន្ធទី២នៃសេចក្តីណែនាំនេះ ដើម្បីដាក់ជូនកិច្ចប្រជុំគណៈអភិបាលពិនិត្យ និងឯកភាព មុននឹងដាក់ជូនកិច្ចប្រជុំក្រុមប្រឹក្សាពិនិត្យ និងអនុម័ត។

តារាងបែងចែកប្រាក់រង្វាន់ដែលទទួលបានការអនុម័តពីក្រុមប្រឹក្សា ត្រូវធ្វើការផ្សព្វផ្សាយតាមអង្គភាពនីមួយៗនៃរដ្ឋបាលរបស់ខ្លួន។

**គ.១.២. សម្រាប់រដ្ឋបាលឃុំ សង្កាត់**

ការបែងចែកប្រាក់រង្វាន់លើកទឹកចិត្តសម្រាប់ឧបត្ថម្ភជូនមន្ត្រី បុគ្គលិក និងសមាជិកក្រុមប្រឹក្សានៃរដ្ឋបាលឃុំ សង្កាត់ ត្រូវធ្វើឡើងតាមការសម្រេចរបស់ក្រុមប្រឹក្សា តាមសំណើរបស់មេឃុំ ចៅសង្កាត់សាមីនីមួយៗ ដោយមានការពិគ្រោះយោបល់និងឯកភាពជាមួយជំទប់ ចៅសង្កាត់រងរបស់ខ្លួន។

ប្រាក់រង្វាន់នេះ ត្រូវធ្វើការបែងចែកសម្រាប់ឧបត្ថម្ភជូនមេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង មន្ត្រី បុគ្គលិកដែលផ្តល់សេវាផ្ទាល់ ព្រមទាំងបុគ្គលិក និងសមាជិកក្រុមប្រឹក្សាផ្សេងៗទៀតដែលបំពេញការងារនៅរដ្ឋបាលឃុំ សង្កាត់របស់ខ្លួន។ ការបែងចែកប្រាក់រង្វាន់នេះ ត្រូវផ្អែកតាម**លទ្ធផល និងប្រសិទ្ធភាពការងារ**របស់បុគ្គលម្នាក់ៗ លើកលែងតែសមាជិកក្រុមប្រឹក្សាផ្សេងៗទៀតដែលត្រូវទទួលបាននូវចំណែកស្មើគ្នា។

ប្រាក់រង្វាន់សម្រាប់បែងចែកជូន**មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង** និង**មន្ត្រី បុគ្គលិកម្នាក់ៗដែលផ្តល់សេវាផ្ទាល់** ត្រូវកំណត់មិនឲ្យ**ទាបជាង២ដង និងមិនឲ្យច្រើនជាង៣ដង**នៃប្រាក់រង្វាន់សម្រាប់ឧបត្ថម្ភជូនសមាជិកក្រុមប្រឹក្សា និង**បុគ្គលិកម្នាក់ៗផ្សេងៗទៀត**ឡើយ។

មន្ត្រីទីប្រឹក្សា មន្ត្រីកិច្ចសន្យាដែលគាំទ្រដោយមូលនិធិរបស់ដៃគូអភិវឌ្ឍន៍នានា មិនត្រូវទទួលបានប្រាក់រង្វាន់នេះឡើយ។

ស្មៀនឃុំ សង្កាត់ត្រូវផ្តួចផ្តើមរៀបចំសេចក្តីព្រាងតារាងបែងចែកប្រាក់រង្វាន់សម្រាប់មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង មន្ត្រី បុគ្គលិកដែលផ្តល់សេវាផ្ទាល់ ព្រមទាំងបុគ្គលិក និងសមាជិកក្រុមប្រឹក្សាផ្សេងៗទៀតដែលបំពេញការងារនៅរដ្ឋបាលឃុំ សង្កាត់របស់ខ្លួន តាមតារាងគំរូក្នុងឧបសម្ព័ន្ធទី១នៃសេចក្តីណែនាំនេះ ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ស្តីពីលទ្ធផលនៃការផ្តល់សេវារដ្ឋបាលរបស់

ខ្លួន ដូចមានទម្រង់គំរូក្នុងឧបសម្ព័ន្ធទី២នៃសេចក្តីណែនាំនេះ ដើម្បីដាក់ជូនមេឃុំ ចៅសង្កាត់ធ្វើការពិគ្រោះយោបល់និងឯកភាពជាមួយជំទប់ ចៅសង្កាត់រងរបស់ខ្លួន មុននឹងដាក់ជូនកិច្ចប្រជុំក្រុមប្រឹក្សាពិនិត្យ និងអនុម័ត។

តារាងបែងចែកប្រាក់រង្វាន់ដែលទទួលបានការអនុម័តពីក្រុមប្រឹក្សា ត្រូវធ្វើការផ្សព្វផ្សាយនៅក្នុងរដ្ឋបាលរបស់ខ្លួន។

**គ.២. ប្រាក់រង្វាន់សម្រាប់ពង្រឹងយន្តការផ្តល់សេវារដ្ឋបាល**

ប្រាក់រង្វាន់សម្រាប់ពង្រឹងយន្តការផ្តល់សេវារដ្ឋបាលនេះ អាចយកទៅប្រើប្រាស់សម្រាប់គាំទ្របន្ថែមដល់កិច្ចប្រតិបត្តិការរដ្ឋបាល សម្ភារ និងមធ្យោបាយរបស់ ៖

- យន្តការ ឬអង្គភាពផ្តល់សេវារដ្ឋបាល ដើម្បីលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវារដ្ឋបាល
- ក្រុមប្រឹក្សា និង
- យន្តការតាមដាន ត្រួតពិនិត្យ សម្រុះសម្រួលដោះស្រាយពាក្យបណ្តឹង។

អភិបាល មេឃុំ ចៅសង្កាត់ ក្នុងនាមក្រុមប្រឹក្សារបស់ខ្លួនត្រូវចាត់ចែង ប្រើប្រាស់ថវិកាទាំងនេះប្រកបដោយតម្លាភាព និងគណនេយ្យភាព ដោយផ្អែកទៅលើតម្រូវការជាក់ស្តែង និងតាមសំណើរបស់យន្តការ ឬអង្គភាពផ្តល់សេវា ក្រុមប្រឹក្សា និងយន្តការតាមដាន ត្រួតពិនិត្យ សម្រុះសម្រួលដោះស្រាយពាក្យបណ្តឹង។

អភិបាល មេឃុំ ចៅសង្កាត់ត្រូវធ្វើសេចក្តីរាយការណ៍ប្រចាំខែជូនក្រុមប្រឹក្សារបស់ខ្លួនអំពីការចាត់ចែង និងការប្រើប្រាស់ថវិកានេះ។

**គ៣. ការបែងចែកប្រាក់រង្វាន់លើកទឹកចិត្តដល់មន្ទីរ អង្គភាព និងការិយាល័យជំនាញ**

ការបែងចែកប្រាក់រង្វាន់លើកទឹកចិត្តដល់មន្ទីរ អង្គភាព និងការិយាល័យជំនាញពាក់ព័ន្ធនានា ដូចដែលបានកំណត់នៅក្នុងតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសអន្តរក្រសួងលេខ ៣៨៤៥ ប្រក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្តីពីការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តជូនរដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗមានភារកិច្ចត្រឹមតែបើកផ្តល់ចំណែកប្រាក់រង្វាន់នោះ ជូនដល់មន្ទីរ អង្គភាព និងការិយាល័យជំនាញពាក់ព័ន្ធទាំងនោះតែប៉ុណ្ណោះ។ មន្ទីរ អង្គភាព និងការិយាល័យជំនាញទាំងនោះមានភារកិច្ចបំពេញសំណុំបែបបទ និងឯកសារផ្សេងៗទៅតាមគោលការណ៍ និងនីតិវិធីតាមការណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ឃ. នីតិវិធីបើកផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត**

ទីចាត់ការហិរញ្ញវត្ថុរាជធានី ខេត្ត ការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុក្រុង ស្រុក ខណ្ឌ និងស្មៀនឃុំ សង្កាត់ មានតួនាទីរៀបចំបើកផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តប្រចាំខែជូនដល់មន្ត្រី បុគ្គលិក ផ្អែកតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា និងបំពេញតួនាទីផ្នែកហិរញ្ញវត្ថុផ្សេងទៀតតាមគោលការណ៍ និងនីតិវិធីជាធរមាន។

## ឆ. ការគ្រប់គ្រងប្រាក់រង្វាន់លើកទឹកចិត្ត

ដំណើរការគ្រប់គ្រងចំណូល ចំណាយ ការកត់ត្រា ការតាមដាន និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវអនុវត្តតាមគោលការណ៍ និងនីតិវិធីនៃការផ្ដល់ប្រាក់រង្វាន់លើកទឹកចិត្តដែលកំណត់ដោយសេចក្ដីណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ច. ការធ្វើរបាយការណ៍

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ នីមួយៗ ត្រូវរៀបចំរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ស្ដីពីលទ្ធផលនៃការផ្ដល់សេវារដ្ឋបាល និងការបែងចែកប្រាក់រង្វាន់លើកទឹកចិត្តរបស់ខ្លួន តាមទម្រង់គំរូដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី៣នៃសេចក្ដីណែនាំនេះ ដោយដាក់បញ្ចូលជាផ្នែកមួយនៃរបាយការណ៍របស់រដ្ឋបាលខ្លួន និងត្រូវអនុវត្តតាមនីតិវិធីនានា ដូចមានកំណត់ក្នុងសេចក្ដីណែនាំលេខ០៣៥សនណ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ របស់ក្រសួងមហាផ្ទៃ ស្ដីពីការរៀបចំរបាយការណ៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ត្រូវទទួលបន្ទុកអនុវត្តនូវសេចក្ដីណែនាំនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

ស ខេង

**<u>ចម្លងជូន</u>** ÷

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- អង្គភាពប្រឆាំងអំពើពុករលួយ
  "ដើម្បីជូនជ្រាប"
- គ្រប់រដ្ឋបាលថ្នាក់ក្រោមជាតិ
  "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

(ក្បាលលិខិត)

## តារាងបែងចែកប្រាក់រង្វាន់លើកទឹកចិត្តដែលបានមកពីការផ្តល់សេវារដ្ឋបាល

## សម្រាប់ឧបត្ថម្ភជូនមន្ត្រី បុគ្គលិកនៃរដ្ឋបាល..................

## សម្រាប់ខែ............ ឆ្នាំ...........

### I. តារាងបែងចែកប្រាក់រង្វាន់លើកទឹកចិត្ត

| ល.រ | បរិយាយ | អាត្រា(%) | ចំនួន (គិតជារៀល) |
|---|---|---|---|
| ១ | ប្រាក់រង្វាន់សម្រាប់ឧបត្ថម្ភជូនមន្ត្រី បុគ្គលិក | | |
| ២ | ប្រាក់រង្វាន់សម្រាប់ពង្រឹងយន្តការផ្តល់សេវារដ្ឋបាល | | |
| សរុប | | | |

### II. តារាងបែងចែកប្រាក់រង្វាន់លើកទឹកចិត្តជូនមន្ត្រី បុគ្គលិកម្នាក់ៗ

| ល.រ | ឈ្មោះមន្ត្រី បុគ្គលិក | ចំនួនសន្ទស្សន៍ | ប្រាក់រង្វាន់ក្នុងមួយសន្ទស្សន៍ | ប្រាក់រង្វាន់សម្រាប់មន្ត្រី បុគ្គលិកម្នាក់ៗ |
|---|---|---|---|---|
| ក). មន្ត្រី បុគ្គលិកផ្តល់សេវាផ្ទាល់ | | | | |
| ក.១. មន្ត្រី បុគ្គលិកផ្តល់សេវាផ្ទាល់ដែលមានការទទួលខុសត្រូវ និងបន្ទុកការងារច្រើន | | | | |
| ១ | | | | |
| ២ | | | | |
| ក.២. មន្ត្រី បុគ្គលិកផ្តល់សេវាផ្ទាល់ដែលមានការទទួលខុសត្រូវ និងបន្ទុកការងារមិនសូវច្រើន | | | | |
| ១ | | | | |
| ២ | | | | |
| ខ. មន្ត្រី បុគ្គលិកផ្សេងៗទៀត | | | | |
| ខ.១. មន្ត្រី បុគ្គលិកផ្សេងៗទៀតដែលមានការទទួលខុសត្រូវ និងបន្ទុកការងារច្រើន | | | | |
| ១ | | | | |
| ២ | | | | |
| ខ.២. មន្ត្រី បុគ្គលិកផ្សេងៗទៀតដែលមានការទទួលខុសត្រូវ និងបន្ទុកការងារមិនសូវច្រើន | | | | |
| ១ | | | | |
| ២ | | | | |
| សរុប | | | | |

តារាងបែងចែកប្រាក់រង្វាន់លើកទឹកចិត្តនេះ ត្រូវបានពិនិត្យ និងអនុម័តនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សា ..........................................នាថ្ងៃទី....... ខែ............ ឆ្នាំ.........។

ធ្វើនៅ............ ថ្ងៃទី..... ខែ.......... ឆ្នាំ.......

**អភិបាល ឬមេឃុំ ចៅសង្កាត់**

**ឧបសម្ព័ន្ធទី២**

(ក្បាលលិខិត)

## របាយការណ៍សង្ខេបស្តីពីលទ្ធផលនៃការផ្តល់សេវារដ្ឋបាល

**សម្រាប់ខែ..........ឆ្នាំ.............**

**ក. ស្ថានភាពនៃការផ្តល់សេវារដ្ឋបាល**

| ល.រ | វិស័យ ឬ ប្រភេទសេវារដ្ឋបាល | ចំនួនសេវា | ចំណូល | ថវិកាបង់ចូលថវិការដ្ឋបាលថ្នាក់ក្រោមជាតិ | | ប្រាក់រង្វាន់សម្រាប់អង្គភាពផ្សេងទៀត | | ប្រាក់រង្វាន់សម្រាប់រដ្ឋបាល | |
|---|---|---|---|---|---|---|---|---|---|
| | | | | % | ចំនួនប្រាក់ | % | ចំនួនប្រាក់ | % | ចំនួនប្រាក់ |
| ១ | | | | | | | | | |
| ២ | | | | | | | | | |
| ៣ | | | | | | | | | |
| ៤ | | | | | | | | | |
| ៥ | | | | | | | | | |
| ៦ | | | | | | | | | |
| ៧ | | | | | | | | | |
| ៨ | | | | | | | | | |
| .... | | | | | | | | | |
| សរុប | | | | | | | | | |

## ខ. ចំនួនប្រាក់រង្វាន់សរុបប្រចាំខែ

| ល.រ | ប្រភពប្រាក់រង្វាន់ | ចំនួន(គិតជារៀល) |
|---|---|---|
| ១ | ប្រាក់រង្វាន់ដែលបានមកពីការផ្តល់សេវារដ្ឋបាលផ្ទាល់ | |
| ២ | ប្រាក់រង្វាន់ដែលបានមកពីការបែងចែកពីក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា | |
| ៣ | ប្រាក់រង្វាន់ដែលបានមកពីការបែងចែកពីថ្នាក់រដ្ឋបាលផ្សេងៗទៀត | |
| សរុប | | |

ធ្វើនៅ............ ថ្ងៃទី..... ខែ.......... ឆ្នាំ.......

**អភិបាល ឬមេឃុំ ចៅសង្កាត់**

**ឧបសម្ព័ន្ធទី៣ "ក"**

## របាយការណ៍ស្ដីពីការផ្ដល់សេវារដ្ឋបាល

## ប្រចាំខែ ឬប្រចាំត្រីមាស ឬប្រចាំឆមាស........ ឆ្នាំ.........

| ល.រ | ការបរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ១ | សេវាសរុបដែលបានផ្ដល់ចប់សព្វគ្រប់ | | | |
| ២ | ប្រជាពលរដ្ឋសរុបដែលបានទទួលសេវា | | | |
| ៣ | ប្រជាពលរដ្ឋជាស្ត្រីដែលបានទទួលសេវា | | | |
| ៤ | ចំណូលដែលបានទទួលពីការផ្ដល់សេវា | | | |
| ៥ | ប្រាក់រង្វាន់សរុបដែលបានបែងចែក | | | |

ទិន្នន័យខាងលើនេះសម្រាប់ដាក់បញ្ចូលជាផ្នែកមួយនៃរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាសរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដូចបានកំណត់ក្នុងសេចក្ដីណែនាំលេខ០៣៥សនណ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ របស់ក្រសួងមហាផ្ទៃ ស្ដីពីការរៀបចំរបាយការណ៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**ឧបសម្ព័ន្ធទី៣ "ខ"**

## របាយការណ៍ស្ដីពីការផ្ដល់សេវារដ្ឋបាល

## ប្រចាំឆ្នាំ...........

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | សេវាសរុបដែលបានផ្ដល់ចប់សព្វគ្រប់ | |
| ២ | ប្រជាពលរដ្ឋសរុបដែលបានទទួលសេវា | |
| ៣ | ប្រជាពលរដ្ឋជាស្ត្រីដែលបានទទួលសេវា | |
| ៤ | ចំណូលដែលបានទទួលពីការផ្ដល់សេវា | |
| ៥ | ប្រាក់រង្វាន់សរុបដែលបានបែងចែក | |

ទិន្នន័យខាងលើនេះសម្រាប់ដាក់បញ្ចូលជាផ្នែកមួយនៃរបាយការណ៍ប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដូចបានកំណត់ក្នុងសេចក្ដីណែនាំលេខ០៣៥សនណ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ របស់ក្រសួងមហាផ្ទៃ ស្ដីពីការរៀបចំរបាយការណ៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។